# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាប្រសិទ្ធីពរលើជួងថ្មីនិងអគ្គសញ្ញាលាបថ្ងាស
# ទឹកឈូក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩
# ជួងរំឭកយើងឲ្យអធិដ្ឋាន

**អត្ថបទទី១៖ កិច្ចការ ២,១-១១**

អ្នកទាំងនោះបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ហើយចាប់ផ្ដើមនិយាយភាសាផ្សេងៗពីគ្នា តាមព្រះវិញ្ញាណប្រោសប្រទានឲ្យ។ កក ២,៤

**អត្ថបទទី២៖ រ៉ូម ៨,៨-១៧**

បងប្អូនអើយ យើងមានជំពាក់ម្យ៉ាង តែមិនមែនជំពាក់ខាងលោកីយ៍ ដើម្បីរស់តាមលោកីយ៍ទៀតឡើយ។ រម ៨,១២

**ដំណឹងល្អ៖ យ៉ូហាន ១៤,១៥-១៦.២៣-២៦**

ព្រះដ៏ជួយការពារ គឺព្រះវិញ្ញាណដ៏វិសុទ្ធដែលព្រះបិតាចាត់ឲ្យមកក្នុងនាមខ្ញុំនឹងបង្រៀនសេចក្តីទាំងអស់ដល់អ្នករាល់គ្នា ព្រមទាំងរំឭកអ្វីៗដែលខ្ញុំបានប្រាប់អ្នករាល់គ្នាផង។ យហ ១៤,២៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងបានចាប់ផ្ដើមដោយសុំព្រះជាម្ចាស់ប្រទានពរលើជួង ដើម្បីឲ្យបងប្អូនដែលនៅជុំវិញព្រះសហគមន៍យើងបានឮសម្លេងនៅពេលយើងវាយ និងនឹកឃើញវត្តមានរបស់ព្រះជាម្ចាស់ និងនឹកឃើញព្រះជាម្ចាស់ដែលកំពុងត្រាស់ហៅយើងដើម្បីអធិដ្ឋាន។ នៅក្នុងអត្ថបទទី២ "**លោកិយនិងព្រះវិញ្ញាណផ្ទុយគ្នា**" លោកិយណែនាំឲ្យយើងរវល់ (យើងអត់មានពេលចូលព្រះវិហារ អត់មានពេលអប់រំជំនឿ អត់មានពេលអធិដ្ឋាន...)។ ប៉ុន្តែ យើងមិនមែនតែរស់នៅតាមលោកិយទេ គឺយើងរស់នៅតាមព្រះវិញ្ញាណដ៏វិសុទ្ធ ថ្ងៃនេះលោកប៉ូលបាននិយាយទៅគ្រីស្តបរិស័ទយើងទាំងអស់ថា "**ប្រយ័ត្ន លោកិយនិងព្រះវិញ្ញាណដ៏វិសុទ្ធផ្ទុយគ្នា យើងជាគ្រីស្តបរិស័ទដែលកើតសារជាថ្មីនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ**"។ យើងបានទទួលជីវិតពីឪពុកម្ដាយមែន យើងត្រូវរស់នៅក្នុងសង្គមមែន យើងត្រូវតែទទួលការអប់រំដើម្បីធ្វើជាមនុស្សពេញលក្ខណៈមែន ក៏ប៉ុន្តែមិនទាន់ល្មមទេប្រសិនបើយើងភ្ជាប់ជាមួយលោកិយតែប៉ុណ្ណឹង បើយើងមិនបានថែរក្សាជីវិតដែលយើងបានទទួលពីព្រះវិញ្ញាណដ៏វិសុទ្ធនៅពេលយើងទទួលពិធីជ្រមុជទឹក មនុស្សយើងបន្តិចម្ដងៗយើងទីជាមនុស្សស្ងិត។ ជីវិតរបស់យើងប្រសិនបើយើងមិនថែរក្សាជីវិតខាងផ្លូវវិញ្ញាណ យើងស្អាតបានមួយភ្លែតប៉ុន្តែបន្តិចម្ដងៗយើងទៅជាមនុស្សស្រពោន។

ថ្ងៃនេះ យើងពោរពេញដោយអំណរសប្បាយ ដោយសារយើងដឹងថាព្រះវិញ្ញាណដ៏វិសុទ្ធរំឭកគឺ "**ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងបម្រើគ្នាទៅវិញទៅមកនៅក្នុងចិត្តស្រឡាញ់**"។

ប្រសិនបើយើងភ្ជាប់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ យើងបម្រើគ្នាទៅវិញទៅមកដោយចិត្តស្រឡាញ់ មិនមែនបម្រើដោយការបង្ខំចិត្ត គ្រីស្តបរិស័ទយើងត្រូវតែបម្រើ។ សន្តិតេរេសានៃព្រះកុមារយេស៊ូ ធ្លាប់និយាយថា "**នៅក្នុងអារាមការម៉ែល យើងឥតមានការងារអស្ចារ្យធ្វើទេ យើងរស់នៅជាបងប្អូនបង្កើតពីមួយថ្ងៃទៅមួយថ្ងៃ ជួនកាលមានបងស្រីខ្លះគួរឲ្យស្អប់ណាស់ ប៉ុន្តែយើងត្រូវតែស្រឡាញ់ គ្រប់ការងារដែលយើងធ្វើពីមួយថ្ងៃទៅមួយថ្ងៃ យើងធ្វើដោយចិត្តស្រឡាញ់**"។ កុំឲ្យយើងគិតវែងឆ្ងាយពេក សូមមើលពីចិត្តរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ គិតពិចារណាតើខ្ញុំបានយកចិត្តទុកដាក់បម្រើដោយចិត្តស្រឡាញ់ឬទេ? ដូចលោកប៉ូលបាននិយាយ "**ប្រសិនបើយើងធ្វើយើងរស់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ**"។

លោកប៉ូលរំឭក "**ធម្មវិន័យទាំងមូលសរុបមកត្រឹមតែពាក្យមួយឃ្លាគឺ អ្នកត្រូវស្រឡាញ់បងប្អូនឯទៀតៗឲ្យបានដូចព្រះយេស៊ូបានស្រឡាញ់យើង**"។ ឲ្យយើងរស់នៅតាមធម្មវិន័យនេះ មិនមែនស្រឡាញ់តាមចិត្ត យើងត្រូវការស្រឡាញ់ដូចព្រះយេស៊ូ ដើម្បីជោគជ័យបានយើងមើលព្រះយេស៊ូ។ បើយើងនៅជិតព្រះវិហារ ពេលយើងឮសម្លេងជួងយើងរត់ចូលនៅក្នុងវិហារដើម្បីអធិដ្ឋាន ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ប្រសិនបើយើងរវល់នៅឆ្ងាយពីព្រះវិហារ ពេលយើងឮសម្លេងជួងយើងគូសសញ្ញាឈើឆ្កាង សូត្រធម៌ សូត្របពិត្រព្រះនាងម៉ារី...។ សម័យដើម នៅម៉ោង ៦ព្រឹក ១២ថ្ងៃត្រង់ ៦ល្ងាច គេវាយជួងនិងគ្រីស្តបរិស័ទទាំងអស់ដែលកំពុងធ្វើការគេសម្រាប់មួយភ្លែតដើម្បីសូត្រធម៌។ យើងមានសំណាងនៅទីនេះយើងមានជួងដើម្បីរំឭកយើងយ៉ាងតិចឲ្យយើងសូត្រធម៌បពិត្រព្រះនាងម៉ារីមួយថ្ងៃបីដង។ យើងធ្វើដូចនេះ ដើម្បីឲ្យយើងរស់នៅស្របតាមព្រះវិញ្ញាណ កុំឲ្យលោកិយជាប់ជាមួយយើងពេក ឲ្យគ្រប់សកម្មភាពដែលយើងធ្វើពីមួយថ្ងៃទៅមួយថ្ងៃទទួលពន្លឺពីព្រះវិញ្ញាណដ៏វិសុទ្ធ មានន័យថាពីសេចក្តីស្រឡាញ់ដ៏ពិសេសរបស់ព្រះជាម្ចាស់។ អាម៉ែន៕